# សេចក្តីណែនាំស្តីពីការបំពេញទិន្នន័យ ក្នុងបញ្ជីកត់ត្រា ផ្នែកប្រពោធនកម្ម

បោះពុម្ពលើកទី១, ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣

កំណត់សម្គាល់ ៖

- បញ្ជីកត់ត្រានេះត្រូវប្រើនៅផ្នែកប្រពោធនកម្ម។
- បិទបញ្ជីនៅថ្ងៃចុងក្រោយនៃខែនីមួយៗ។
- សម្រាប់ខែថ្មី កាលបរិច្ឆេទត្រូវសរសេរនៅចំកណ្តាលទំព័រថ្មីនៃសៀវភៅកត់ត្រា។

ត្រូវបំពេញព័ត៌មានលម្អិតនៅបន្ទាត់ (ជួរផ្តេក) តាមការណែនាំខាងក្រោមនូវគ្រប់ករណីទាំងអស់ ៖

| ខ្ទង់ទី | សេចក្តីណែនាំ |
|---|---|
| ១ | *លេខរៀង*<br>ជាលេខរៀង(លេខស្ទីត)តាមលំដាប់។ លេខរៀងនេះត្រូវចាប់ផ្តើមពីលេខ ១ និងលេខបន្តបន្ទាប់រហូតដល់ដាច់ខែ។ ចាប់ផ្តើមលេខរៀងថ្មី(លេខស្ទីត)នៅរៀងរាល់ខែថ្មី។ |
| ២ | *លេខកូដអ្នកជំងឺ*<br>ត្រូវចម្លងលេខពីលេខកូដអ្នកជំងឺរបស់មន្ទីរពេទ្យ។ ឧទាហរណ៍៖ 000-000-123-1។ |
| ៣ | *ឈ្មោះអ្នកជំងឺ*<br>សរសេរឈ្មោះពេញ (នាមត្រកូល និងនាមខ្លួន) របស់អ្នកជំងឺ។ |
| ៤ | *ឈ្មោះអាណាព្យាបាល (សម្រាប់កុមារ)*<br>សរសេរឈ្មោះពេញ (នាមត្រកូល និងនាមខ្លួន) របស់អាណាព្យាបាលកុមារ។ |
| ៥ | *អាយុ៖ 0-២៨ ថ្ងៃ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី 0ថ្ងៃ រហូតដល់ ២៨ថ្ងៃ។ ឧទាហរណ៍៖ អាយុ ២0ថ្ងៃ សរសេរលេខ ២០។ |
| ៦ | *អាយុ៖ ២៩ថ្ងៃ-១១ខែ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ២៩ថ្ងៃ រហូតដល់ ១១ខែ។ ឧទាហរណ៍៖ អាយុ ៣0ថ្ងៃ ឬ ១0ខែ ត្រូវសរសេរបញ្ជាក់ថ្ងៃ ឬខែអោយច្បាស់។ |
| ៧ | *អាយុ៖ ១-៤ ឆ្នាំ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ១ឆ្នាំ រហូតដល់ ៤ឆ្នាំ។ ឧទាហរណ៍៖ អាយុ ៣ឆ្នាំ សរសេរ ៣។ |
| ៨ | *អាយុ៖ ៥-១៤ ឆ្នាំ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ៥ឆ្នាំ រហូតដល់ ១៤ឆ្នាំ។ ឧទាហរណ៍៖ អាយុ ៥ឆ្នាំ សរសេរ ៥។ |
| ៩ | *អាយុ៖ ១៥-២៤ ឆ្នាំ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ១៥ឆ្នាំ រហូតដល់ ២៤ឆ្នាំ។ ឧទាហរណ៍៖ អាយុ ២០ឆ្នាំ សរសេរ ២០។ |

| ខ្ទង់ទី | សេចក្តីណែនាំ |
|---|---|
| ១០ | *អាយុ៖ ២៥-៤៩ ឆ្នាំ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ២៥ឆ្នាំ រហូតដល់ ៤៩ឆ្នាំ។ ឧទាហរណ៍៖ អាយុ ៣៥ឆ្នាំ សរសេរ ៣៥។ |
| ១១ | *អាយុ៖ ៥០-៦៤ ឆ្នាំ*<br>សរសេរអាយុជាក់ស្តែង បើអ្នកជំងឺមានអាយុចាប់ពី ៥០ឆ្នាំ រហូតដល់ ៦៤ឆ្នាំ។ ឧទាហរណ៍៖ អាយុ ៥៥ឆ្នាំ សរសេរ ៥៥។ |
| ១២ | *អាយុ៖ ≥៦៥ ឆ្នាំ*<br>សរសេរអាយុជាក់ស្តែង បើអ្នកជំងឺមានអាយុចាប់ពី ៦៥ឆ្នាំ ឡើងទៅ។ ឧទាហរណ៍៖ អាយុ ៦៦ឆ្នាំ សរសេរ ៦៦។ |
| ១៣ | *ភេទ៖ ប្រុស*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺភេទប្រុស។ ឧទាហរណ៍៖ ១, ២, ៣... |
| ១៤ | *ភេទ៖ ស្រី*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺភេទស្រី។ ឧទាហរណ៍៖ ១, ២, ៣... |
| ១៥ | *អាស័យដ្ឋានបច្ចុប្បន្ន និងលេខទូរស័ព្ទ*<br>សរសេរអាស័យដ្ឋានបច្ចុប្បន្នរបស់អ្នកជំងឺដែលមកទទួលសេវាមន្ទីរពេទ្យ។ ត្រូវសរសេរភូមិ ឃុំ/សង្កាត់ ស្រុក/ក្រុង/ខណ្ឌ រាជធានី/ខេត្ត និងលេខទូរស័ព្ទ។ |
| ១៦ | *បញ្ជូនមកពី*<br>សរសេរឈ្មោះទីកន្លែងដែលបានបញ្ជូនអ្នកជំងឺមក។ ឧទាហរណ៍៖ មណ្ឌលសុខភាព ខ។ |
| ១៧ | *រោគវិនិច្ឆ័យចូល*<br>សរសេររោគវិនិច្ឆ័យដែលគ្រូពេទ្យបានកំណត់។ |
| ១៨ | *ថ្ងៃខែឆ្នាំចាប់ផ្តើមឈឺ*<br>សរសេរថ្ងៃខែឆ្នាំ ដែលអ្នកជំងឺចាប់ផ្តើមឈឺ (មុនពេលមកមន្ទីរពេទ្យលើកនេះ)។<br>ឧទាហរណ៍៖ អ្នកជំងឺចូលសម្រាកពេទ្យថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៣ ប៉ុន្តែចាប់ផ្តើមឈឺនៅថ្ងៃទី ០៥ ខែមករា ឆ្នាំ២០១៣ *ត្រូវសរសេរ ០៥/០១/២០១៣*។ |
| ១៩ | *ថ្ងៃខែឆ្នាំ/ម៉ោងចូល*<br>សរសេរថ្ងៃខែឆ្នាំ/ម៉ោង ដែលអ្នកជំងឺចាប់ផ្តើមចូលសម្រាកពេទ្យ។<br>ឧទាហរណ៍៖ អ្នកជំងឺចូលសម្រាកពេទ្យថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៣ ម៉ោង២៣.០០ *ត្រូវសរសេរ ១០/០១/២០១៣ ម៉ ២៣.០០* ។ |
| ២០ | *អមវេជ្ជសាស្ត្រ*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើគ្រូពេទ្យស្នើសុំសេវាអមវេជ្ជសាស្ត្រ។ ឧទាហរណ៍៖ ១, ២, ៣... |
| ២១ | *ថ្ងៃខែឆ្នាំ/ម៉ោងចេញ*<br>សរសេរថ្ងៃខែឆ្នាំ/ម៉ោង ដែលអ្នកជំងឺបានចេញពីមន្ទីរពេទ្យ។<br>ឧទាហរណ៍៖ អ្នកជំងឺចេញពីមន្ទីរពេទ្យនៅថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៣ ម៉ោង១៥.០០ *ត្រូវសរសេរ ១៤/០១/២០១៣ ម៉ ១៥.០០*។ |
| ២២ | *រោគវិនិច្ឆ័យចេញ*<br>សរសេររោគវិនិច្ឆ័យចេញនៅពេលអ្នកជំងឺចេញពីមន្ទីរពេទ្យ។ |
| ២៣ | *ទម្រង់នៃអ្នកជំងឺចេញ៖ អនុញ្ញាត*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺត្រូវបានអនុញ្ញាតអោយចេញពីមន្ទីរពេទ្យ។ ឧទាហរណ៍៖ ១, ២, ៣... |
| ២៤ | *ទម្រង់នៃអ្នកជំងឺចេញ៖ មិនអនុញ្ញាត*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺបានចេញពីមន្ទីរពេទ្យដោយគ្មានការអនុញ្ញាត ឬស្នើសុំចេញពីមន្ទីរពេទ្យដោយករណីផ្សេងៗ (អ្នកជំងឺត្រូវបានស្នើសុំទៅព្យាបាលនៅផ្ទះ ឬកន្លែងផ្សេងទៀតដោយស្ថានភាពជំងឺពុំទាន់បានធូរស្រាល)។ ឧទាហរណ៍៖ ១, ២, ៣... |

| ខ្ទង់ទី | សេចក្ដីណែនាំ |
|---|---|
| ២៥ | *ទម្រង់នៃអ្នកជំងឺចេញ៖ បញ្ជូន*<br>សរសេរលេខរៀង(លេខស៊ើត)តាមលំដាប់ ប្រសិនបើអ្នកជំងឺត្រូវបានបញ្ជូនចេញពីមន្ទីរពេទ្យ ឬទៅកាន់មូលដ្ឋានសុខាភិបាលណាផ្សេង (សរសេរឈ្មោះមូលដ្ឋានសុខាភិបាល/សេវាឯកជនផ្សេងៗនៅក្នុងខ្ទង់សម្គាល់)។ ឧទាហរណ៍៖ ១, ២, ៣... |
| ២៦ | *ទម្រង់នៃអ្នកជំងឺចេញ៖ ស្លាប់<៤៨*<br>សរសេរលេខរៀង(លេខស៊ើត)តាមលំដាប់ បើអ្នកជំងឺស្លាប់ក្រោម ៤៨ ម៉ោង។ ឧទាហរណ៍៖ ១, ២, ៣... |
| ២៧ | *ទម្រង់នៃអ្នកជំងឺចេញ៖ ស្លាប់ ≥៤៨*<br>សរសេរលេខរៀង(លេខស៊ើត)តាមលំដាប់ បើអ្នកជំងឺស្លាប់ត្រឹម ឬលើស ៤៨ ម៉ោង។ ឧទាហរណ៍៖ ១, ២, ៣... |
| ២៨ | *មូលហេតុស្លាប់*<br>សរសេរមូលហេតុផ្សេងៗ ដែលទាក់ទងទៅនឹងការស្លាប់របស់អ្នកជំងឺ។ |
| ២៩ | *មរណភាពមាតា*<br>សរសេរលេខរៀង(លេខស៊ើត)តាមលំដាប់ ប្រសិនបើមានករណីម្ដាយស្លាប់កំឡុងពេលមានផ្ទៃពោះ/សម្រាលកូន និង៤២ថ្ងៃក្រោយសម្រាលកូន (សរសេរមូលហេតុស្លាប់នៅក្នុងខ្ទង់សម្គាល់)។ ឧទាហរណ៍៖ ១, ២, ៣... |
| ៣០ | *ស្ថានភាពអ្នកជំងឺពេលចេញ*<br>សរសេរលេខកូដសម្រាប់ស្ថានភាពចេញរបស់អ្នកជំងឺដែលបានចេញពីមន្ទីរពេទ្យទោះបីក្នុងករណី អនុញ្ញាត មិនអនុញ្ញាត បញ្ជូន ឬស្លាប់។<br>(១) ជាសះស្បើយ (២) ធូរស្រាល (៣) មិនមានការធូរស្រាល (៤) រិតតែធ្ងន់ធ្ងរ និង (៥) អស់សង្ឃឹម + ស្ថានភាពពិការដោយសារផលវិបាកនៃជំងឺ ឬគ្រោះថ្នាក់ផ្សេងៗ យកតែករណីសម្រាកពេទ្យលើកនេះប៉ុណ្ណោះ (A1=ពិការកាយសម្បទា, A2=ពិការសតិបញ្ញា, A3=ពិការផ្លូវចិត្ត, A4=ពិការផ្សេងៗ)។<br>ឧទាហរណ៍៖ ជាសះស្បើយ និងពិការកាយសម្បទា = ១A1<br>*សម្គាល់៖ សូមមើលប្រកាសអន្តរក្រសួង ស្ដីពីការកំណត់លក្ខណវិនិច្ឆ័យប្រភេទ និងកម្រិតពិការភាព របស់ក្រសួងសុខាភិបាលចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ នៅក្នុងឧបសម្ព័ន្ធនៃមគ្គុទេសន៍ណែនាំសម្រាប់ការបណ្ដុះបណ្ដាលស្ដីពីការប្រើប្រាស់បញ្ជីកត់ត្រាផ្នែកប្រព័ន្ធព័ត៌មានសុខាភិបាល ឬចូលទៅកាន់ Menu ការផ្សព្វផ្សាយនៃគេហទំព័រ www.hiscambodia.org។* |
| ៣១ | *ចំនួនថ្ងៃសម្រាកពេទ្យ*<br>សរសេរចំនួនថ្ងៃពិតប្រាកដដែលអ្នកជំងឺបានសម្រាកពេទ្យ។<br>ឧទាហរណ៍៖ ចូលសម្រាកពេទ្យថ្ងៃទី ០៥/០១/២០១៣ ហើយចេញពីមន្ទីរពេទ្យថ្ងៃទី ១០/០១/២០១៣ ដូច្នេះចំនួនថ្ងៃសម្រាកពេទ្យគឺ ០៦ថ្ងៃ (យកថ្ងៃចេញ ដក ថ្ងៃចូល បូកនិង ១) *ត្រូវសរសេរលេខ ០៦។*<br>*និយមន័យសម្រាកពេទ្យ៖ គឺអ្នកជំងឺដែលគ្រូពេទ្យបានអនុញ្ញាតអោយសម្រាកពេទ្យនៅសាល/អគារ ដោយមិនគិតពីពេលវេលា។* |
| ៣២ | *ប្រភេទនៃការបង់ថ្លៃសេវា*<br>1. សរសេរ P: សម្រាប់ការបង់លុយដោយខ្លួនឯង។<br>2. សូមសរសេរ HEF: សម្រាប់ការបង់ដោយគំរោងមូលនិធិសមធម៌។<br>3. សូមសរសេរ CBHI: សម្រាប់ការបង់ដោយគំរោងធានារ៉ាប់រងសហគមន៍។<br>4. សូមសរសេរ V(Voucher): ប្រសិនបើគាត់មានប័ណ្ណសុខភាព។<br>5. សូមសរសេរ E: សម្រាប់ករណីលើកលែង។<br>*ចំណាំ៖ រាល់ការរបង់ថ្លៃសេវាដោយ HEF ឬ CBHI ឬ V សូមសរសេរលេខកូដដែលស្រង់ចេញពីប័ណ្ណនោះក្នុងខ្ទង់សម្គាល់។* |
| ៣៣ | *សម្គាល់*<br>សរសេរចំនុចសម្គាល់ផ្សេងៗ ដែលចាំបាច់ទាក់ទងទៅនឹងអ្នកជំងឺ។ |

# សម្រង់តួលេខប្រចាំថ្ងៃ ផ្នែកប្រពោធនកម្មសម្រាប់មន្ទីរពេទ្យ

នៃខែ..............ឆ្នាំ.............

| រោគវិនិច្ឆ័យ | អាយុ Group | ករណី | ភេទ | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 | Total |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| (សរសេររោគវិនិច្ឆ័យ) | (សរសេរក្រុមអាយុ) | ឈឺ | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | ស្លាប់ | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ខ. ដាច់សរសៃឈាមខួរក្បាល | ≥65ឆ្នាំ | ឈឺ | ប្រុស | | 1 | | | 1 | 1 | | | | | | | | | | | | | | | | | | | | | | | | | | មិនបាច់បំពេញ |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | ស្លាប់ | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | បញ្ជូនទៅ | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | HEF: បង់ដោយមូលនិធិសមធម៌ | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

មន្ទីរពេទ្យ៖.....................................
ផ្នែក៖.............................................

# ចលនាជំងឺប្រចាំថ្ងៃ ផ្នែកសង្គ្រោះបន្ទាន់សម្រាប់មន្ទីរពេទ្យ

ខែ.........................នៃឆ្នាំ...................
ចំនួនថ្ងៃនៃខែ៖..................................

| សកម្មភាព | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 | Total |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួនគ្រែនៅក្នុងផ្នែក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចំនួនអ្នកជំងឺចេញដោយមានការអនុញ្ញាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចំនួនអ្នកជំងឺចេញដោយគ្មានការអនុញ្ញាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចំនួនអ្នកជំងឺបញ្ជូនចេញ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចំនួនអ្នកជំងឺស្លាប់ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| មរណភាពមាតា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| P: ចំនួនអ្នកជំងឺបង់លុយដោយខ្លួនឯង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| HEF: ចំនួនអ្នកជំងឺបង់ដោយគំរោងមូលនិធិសមធម៌ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| CBHI: ចំនួនអ្នកជំងឺបង់គំរោងធានារ៉ាប់រងសុខភាពសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| V: ចំនួនអ្នកជំងឺបង់ដោយប័ណ្ណសុខភាព | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| E: ចំនួនអ្នកជំងឺដែលជាករណីលើកលែង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចំនួនអ្នកជំងឺបញ្ជូនចូលពីផ្នែកផ្សេងៗ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចំនួនអ្នកជំងឺបញ្ជូនចេញទៅផ្នែកផ្សេងៗ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចំនួនថ្ងៃសម្រាកព្យាបាល *EHD* | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| អត្រាស្លាប់ក្នុងមន្ទីរពេទ្យ (1) % | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រយៈពេលសម្រាកព្យាបាលមធ្យម (2) | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| អត្រាប្រើប្រាស់គ្រែ (BOR) (3) % | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

(1). (ចំនួនស្លាប់/ចំនួនសរុបនៃការចេញពីមន្ទីរពេទ្យ) X ១០០(ចេញដោយមានការអនុញ្ញាត រត់ បញ្ជូន ស្លាប់) (2). ចំនួនថ្ងៃសម្រាកព្យាបាល/ចំនួនសរុបនៃការចេញពីមន្ទីរពេទ្យ (3). (ចំនួនថ្ងៃសំរាកព្យាបាល X ១០០) / (ចំនួនគ្រែ X ចំនួនថ្ងៃនៃខែ)